# សិក្ខាសាលាមជ្ឈមណ្ឌលពាណិជ្ជកម្មសហគមន៍

មជ្ឈមណ្ឌលពាណិជ្ជកម្មសហគមន៍ កើតឡើងដោយការរួមគ្នារវាងអ្នកភូមិនៅក្នុងភូមិដែលមានការសហការគ្នាចូលជាភាគហ៊ុនរួមគ្នាបើកលក់ ហើយការបើកលក់នេះគឺក្នុងគោលបំណងកាត់បន្ថយការចំណាយទៅក្រៅ ការបង្កើតអាជីពការងារដល់អ្នកភូមិ ការរកទីផ្សារសំរាប់កសិករដែលមានផលិតផលលក់ ជាពិសេសគឺផលិតផលក្នុងស្រុក ។ ដូច្នេះបានជានៅថ្ងៃទី ០៧-០៨ ខែ តុលា ឆ្នាំ ២០០៨ អង្គការសេដាក បានរៀបចំបើកសិក្ខាសាលាមួយវគ្គនេះឡើងនៅការិយាល័យបណ្តាញកសិករ និងធម្មជាតិជូនចំពោះផ្សារថ្នាក់កម្រងណា ដែលមានការសហការជាមួយ សេដាក ដែលសរុបមានចំនួន ៩ ផ្សារ ។ ចំពោះផ្សារដែលកំពុងតែសាងសង់ និងចាប់ផ្តើមរៀបចំលក់បណ្តើរៗ មានការជំនួយប្រាក់ឧបត្ថម្ភពីសមាគមកសិករអន្តរជាតិ AFA ។ សិក្ខាសាលានេះមានការសម្របសម្រួលពីលោក ជា ឈួន និង លោក តាត់ សុខ និងមានអ្នកចូលរួមសរុបចំនួន ២៣ នាក់ ( ស្ត្រី ២ នាក់) មកពី ៥ ខេត្ត ។ គោលបំណងសំខាន់ៗនៃសិក្ខាសាលានេះរួមមានៈ



- ចែករំលែកបទពិសោធន៍ និងរៀនសូត្រពីគ្នា
- ឆ្លុះបញ្ចាំងពីភាពរីកចំរើននៅតាមតំបន់នីមួយៗ
- ការជជែកពីរឿងបញ្ជីស្នាមគ្រប់គ្រងផ្សារ
- លេងល្បែងបង្កើនគំនិតទាក់ទងនឹងគំនិតធ្វើជំនួញ ។

ជាសរុបមកយើងឃើញថាសិក្ខាសាលមួយវគ្គនេះពិតជាសំខាន់ណាស់ ទាក់ទងនឹងការធ្វើផែនការជំនួញ និងការគ្រប់គ្រងលើបញ្ជីស្នាមដើម្បីធ្វើអោយផ្សាររបស់គេមានដំណើរការទៅមុខដោយរលូន ព្រោះកាលណាផ្សារអាចមានដំណើរការទៅមុខដោយរលូនបានសំខាន់ទាក់ទងនឹងកត្តា ២ យ៉ាងគឺៈ ទី ១ គឺការគ្រប់គ្រងដឹងពីតួនាទី និងស្មោះត្រង់ ទី ២ ទាក់ទងនឹងការគ្របគ្រងលើបញ្ជីស្នាមអោយបានច្បាស់លាស់ ។